# កិច្ចព្រមព្រៀងវិនិយោគធុនធំ

តំបន់ភ្នំដែក ស្រុករវៀង ខេត្តព្រះវិហារ

រវាង

# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

និង

# ក្រុមហ៊ុនដែលខុមកម្ពុជា

1994

# កិច្ចព្រមព្រៀងវិនិយោគទុន រ៉ែ

កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ១៩៩៨

រវាង

- រាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ហៅកាត់ថា " ក្រសួង "

និង

- ក្រុមហ៊ុន DELCOM CAMBODIA PTE. LTD. ដែលជាក្រុមហ៊ុនមួយត្រូវបានបង្កើតឡើង ស្របតាមច្បាប់របស់ប្រទេស កម្ពុជា ហៅកាត់ថា " អ្នកចុះកិច្ចសន្យា " ។

# សេចក្តីបញ្ជាក់

ដោយហេតុថារដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រ កម្ពុជាប្រកាសថាធនធានរ៉ែដែលមាននៅក្នុងទឹកដីនៃព្រះរាជាណាចក្រ កម្ពុជា ជាកម្មសិទ្ធិរបស់ប្រជាជនកម្ពុជាទាំងមូល និង នៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ។

- ដោយហេតុថាក្រុមហ៊ុនបានដាក់ពាក្យសុំលិខិតអនុញ្ញាតិស្វែងរុករក និង មានគោលបំណងសុំលិខិតអនុញ្ញាតិជីកយករ៉ែ ត្បូងទ្រាយធំ ក្នុងតំបន់ ភ្នំដែក ខេត្តព្រះវិហារ និង ជីកយករ៉ែកិច្ចអាជីវកម្ម ពាណិជ្ជកម្មដែលរកឃើញនៅក្នុងតំបន់ មាន លិខិតអនុញ្ញាតិស្វែងរុករក ។
- ដោយហេតុថារាជរដ្ឋាភិបាលមានបំណងជំរុញ និង លើកទឹកចិត្តការស្វែងរុករក និង ជីកយករ៉ែ ជាទូទៅហើយដោយ ឡែកតំបន់ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ និង
- ដោយហេតុថា រាជរដ្ឋាភិបាលមានបំណងជំរុញការវិនិយោគលើវិស័យផលិតកម្មផលិតផលនាំចេញ និង ផលិតផល ដែលអាចជំនួស ផលិតផលចាំបាច់ដែលត្រូវនាំចូល ហើយជំរុញការប្រើប្រាស់វត្ថុធាតុដើម និង ធនធានធម្មជាតិដែល មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ដោយហេតុថារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវបានទទួលអំណាច ដើម្បីអនុវត្តន៍កិច្ចព្រមព្រៀង វិនិយោគទុនរ៉ែជាមួយក្រុមហ៊ុន ។
- អាស្រ័យហេតុនេះដើម្បីបញ្ជាក់ការសន្យា និង លក្ខខ័ណ្ឌទៅវិញទៅមកដែលបានបង្កើតឡើង ភាគីទាំងពីរឯកភាព គ្នាដើម្បីធ្វើប្រតិបត្តិការ រ៉ែនៅតំបន់ ភ្នំដែក ខេត្តព្រះវិហារ ដូចតទៅ

- ១ -

## ជំពូក ១

## ខ្លឹមសារ និងការបកស្រាយ

ប្រការ ១. ខ្លឹមសារភូម

១.១ កម្មវត្ថុនៃកិច្ចព្រមព្រៀងនេះគឺការស្វែងរុករក ការអភិវឌ្ឍន៍ និងយករ៉ែនៅក្នុងតំបន់មានលិខិតអនុញ្ញាតិស្វែងរុករក ។

១.២ តំបន់មានលិខិតអនុញ្ញាតិស្វែងរុករកមាន ពីររយដប់ប្រាំមួយ ( ២១៦ ) គីឡូម៉ែត្រក្រឡាដែល មានកូអរដោនេបញ្ជាក់ក្នុងឧបសម្ព័ន្ធ ១ និង ដែលមានផែនទីបញ្ជាក់ ក្នុងឧបសម្ព័ន្ធ ២ និង ៣ ។

១.៣ អ្នកចុះកិច្ចសន្យាត្រូវធានាខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល អំពីការអនុវត្តន៍កិច្ចប្រតិបត្តិការដោយគោរពតាមសេចក្តីបញ្ជាក់ទាំងឡាយ ដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ និងនៅក្រោមការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល ។ អ្នកចុះកិច្ចសន្យាគឺជាអង្គភាពស្របច្បាប់តែមួយគត់ ដែលមានសិទ្ធិនិងភារកិច្ចផ្តាច់មុខ ក្នុងការអនុវត្តន៍ កិច្ចប្រតិបត្តិការរ៉ែ នៅតំបន់មានលិខិតអនុញ្ញាតិស្វែងរុករកក្នុងរយៈពេលនៃកិច្ចព្រមព្រៀងនេះ ។

១.៤ ក្រសួង មានមានភារៈកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងជួសមុខអោយរាជរដ្ឋាភិបាល ក្នុងកិច្ចប្រតិបត្តិការរ៉ែ ដែលមានចែងក្នុងប្រការខាងក្រោមនេះ ។

១.៥ អ្នកចុះកិច្ចសន្យាត្រូវផ្តល់ទុនគ្រប់គ្រាន់ បច្ចេកវិជ្ជា និងកំលាំងពលកម្មចាំបាច់សំរាប់អនុវត្តន៍កិច្ចប្រតិបត្តិការរ៉ែ លើកលែងតែមានប្រការដោយឡែក ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ។

១.៦ អ្នកចុះកិច្ចសន្យាត្រូវអនុវត្តកិច្ចប្រតិបត្តិការរ៉ែដោយគ្រោះសោហ៊ុយចំណាយនិងទទួលខាតបង់ផ្ទាល់ខ្លួន លើកលែងតែមានប្រការដោយឡែកដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។ សោហ៊ុយចំណាយដែលអ្នកចុះកិច្ចសន្យាបានប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការរ៉ែ នឹងត្រូវបានស្រង់យកវិញ ដោយអ្នកចុះកិច្ចសន្យាស្របតាមជំពូក ៤ ។ ប្រសិនបើក្នុងតំបន់មានលិខិតអនុញ្ញាតិស្វែងរុករកពុំមានការរកឃើញ ជំរករ៉ែដែលមានគុណតម្លៃពាណិជ្ជកម្មទេ ឬប្រសិនបើផលិតផលដែលទទួលបានពុំគ្រប់គ្រាន់ដើម្បីជាន់សង អោយអ្នកចុះកិច្ចសន្យាបានទេនោះ អ្នកចុះកិច្ចសន្យាត្រូវទទួលខាតបង់ដោយផ្ទាល់ខ្លួន ។

១.៧ កាលបរិច្ឆេទជាមាននៃកិច្ចព្រមព្រៀងនោះគឺជាថ្ងៃដែលកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរ ។

១.៨ នៅពេលដែលច្បាប់រ៉ែចូលជាធរមាន រាល់បញ្ញត្តិនិងលក្ខខណ្ឌទាំងឡាយនៃ ច្បាប់ត្រូវយកជាគោល ។ អាស្រ័យហេតុនេះកិច្ចព្រមព្រៀងនេះត្រូវពិនិត្យឡើងវិញនិងកែសំរួល អោយបានស្របគ្នាលើកលែងតែល័ក្ខខ័ណ្ឌសំខាន់ៗ ដូចជាល័ក្ខខ័ណ្ឌចែងផែកផល ពន្ធអាករ សួយសារ និង ឈ្នួលដី ។

ប្រការ ២. ការបកស្រាយ

ចំណងជើងដែលប្រើនៅក្នុងកិច្ចព្រមព្រៀងនេះគ្រាន់តែដើម្បីងាយស្រួលក្នុងការនិយាយយោងដល់តែប៉ុណ្ណោះ ហើយគ្មានឥទ្ធិពលអ្វីទៅលើការបកស្រាយបញ្ញត្តិណាមួយឡើយ ។